# ប្រវត្តិនៃថ្ងៃបុណ្យ Saint Valentin

សព្វថ្ងៃនេះ យើងគ្រប់ៗគ្នាយល់ឃើញថា Saint Valentin ជាថ្ងៃបុណ្យនៃពាណិជ្ជកម្ម, បង្កើតឡើងដោយឈ្មួញលក់ផ្កា ដោយសារបាត់បង់នូវកម្រៃរបស់ខ្លួន។ ប៉ុន្តែការពិត គឺវាផ្សេងពីនេះទៅវិញ លោកអ្នកអាចយល់បានដោយអាននូវរឿងខាងក្រោម៖

ដំបូងគួរបញ្ជាក់ថា ប្រវត្តិនៃ Saint Valentin គឺជារឿងដ៏ចំណាស់ដូចជារឿង Père Noël ឬ Santa Claus ដែរ តែគ្មានមជ្ឈដ្ឋានណាទទួលស្គាល់ទៀតផង។ ម្តងទៀតហើយ ទាំងអស់នេះបានចាប់ផ្តើមនៅទីក្រុងរ៉ូមប្រទេសអ៊ីតាលី ពីរឬបីសតវត្សរ៍(ស.វ.) មុនយុគសម័យយើងបច្ចុប្បន្ន។ រាល់ថ្ងៃ ១៥ កុម្ភៈ ពួករ៉ូម៉ាំងធ្វើពិធីបុណ្យ Lupercales ឧទ្ទិសចំពោះព្រះអាទិទេព Faunus ។ អាទិទេព Faunus ជាកូនចៅរបស់ Saturne(ស្មើនឹង Chronos របស់ក្រិក)។ Faunus ជាអាទិទេពការពារនូវហ្វូងសត្វ (ចៀម) នឹងពហុផលភាព ហើយហ្វូនុស ក៏វាយប្រហារផងដែរដល់ពពួកឆ្កែចចក(loups ឬ wolfs) ហើយដែលមានសម្មតិនាមថា Lupercus( lupus មានន័យថាឆ្កែចចក ជាភាសាឡាតាំង) ។ ជាញឹកញយ មានរូបតំណាងដោយមានជើងនឹងស្នែងពពែ, អាទិទេពនេះត្រូវបានគេបញ្ចូលជាមួយអាទិទេពPan នៅក្នុងទេវកថារបស់ជនជាតិក្រិក។

ថ្ងៃ ១៥ កុម្ភៈ ពួកបព្វជិត Luperques ដែលគោរពអាទិទេព Faunus ចំនួន ១២ រូប(សុទ្ធតែជាក្មេងប្រុសជំទង់ៗ) បានជួបជុំគ្នានៅក្នុងគុហា Lupercal នៅជើងភ្នំ Palentin (ហើយដែលនៅទីនេះផងដែរដែល Remus នឹង Romulus ត្រូវបានបំបៅដោះដោយមេឆ្កែចចក,នេះបើតាមរឿងព្រេង)។ បព្វជិតទាំង ១២ រូបស្លៀកពាក់ដោយសំពត់ប៊ឹងធម្មតា បានយកពពែឈ្មោលមួយមកធ្វើពិធីបូជាយញ្ញ រួច បព្វជិតនៃពិធីនេះ បានយកកាំបិតដែលប្រឡាក់ដោយឈាមនៅលើថ្ងាសនៃបព្វជិតLuperquesទាំង ១២ ឈាមនៅលើថ្ងាសនោះត្រូវបានជូតឡើងវិញដោយក្រណាត់ឡែនបានជ្រលក់ក្នុងទឹកដោះគោជាមុន។ ខណៈនោះ

ហើយដែលយុវជនទាំង១២ បានសើចក្អាកក្អាយហើយបានរត់ទៅតាមដងផ្លូវនៃទីក្រុងរ៉ូម។ ម្នាក់ៗមានរំពាត់ខ្សែតីធ្វើពីស្បែកពពែ, ហើយពួកគេបានដេញវាយដល់ពពួកយុវតី ដើម្បីឲ្យពួកស្រីៗទាំងនោះកុំឲ្យមានភាពអា( ពពែជានិមិត្តរូបនៃការឲ្យផល )។

Saint Valentin ឈ្មោះពិត Valentin de Terni (វ៉ាឡង់តាំងដឺទានី), ជាបព្វជិតមួយរស់នៅទីក្រុងរ៉ូមនៅអំឡុងស.វ.ទី៣នៃគ្រិស្តសករាជ(គ.ស.) ( ប្រភពខ្លះថាគាត់ជាអេវ៉េក(évêque))។ បព្វជិតដ៏គួរគោរពនេះ មានឈ្មោះល្បីក្នុងការរៀបអាពាហ៍ពិពាហ៍តាមសាសនាគ្រិស្តហើយតែងតែជួយដល់គ្រិស្តបរិសទ្យណាដែលត្រូវគេធ្វើទុក្ខបុកម្នេញ។ អធិរាជ Claude II le Gothique(ខ្លូដទី២ឡឺហ្គោទីក), ដោយបានដឹងអំពីការប្រព្រឹត្តិរបស់ វ៉ាឡង់តាំង ក៏បានសម្រេចចិត្តចាប់វ៉ាឡង់តាំង ដាក់ពន្ធនាគារ។នៅក្នុងបន្ទប់ឃុំឃាំង, បព្វជិតវ៉ាឡង់តាំងបានជួបជាមួយ Julia (ហ្ស៊ុយល្យ៉ា) កូនស្រីរបស់ឆ្មាំគុក។ យុវតីនេះខ្វាក់ភ្នែកតាំងពីកំណើត បានរាប់អានគ្នាជាមិត្តជាមួយទណ្ឌិតនេះ។

បន្ទាប់មក នៅថ្ងៃមួយយុវតីនេះ បានភ្លឺភ្នែកនឹងមើលឃើញឡើងវិញ នៅពេលដែលនាងកំពុងសន្ទនាជាមួយ វ៉ាឡង់តាំង។ វ៉ាឡង់តាំង ត្រូវបានគេនាំយកទៅបង្ហាញនៅចំពោះមុខអធិរាជភ្លាមៗ( Valentin ក៏បានព្យាយាមបញ្ចុះបញ្ចូលអធិរាជឲ្យក្លាយជាគ្រិស្តសាសនិក តែមិនបានសម្រេច)។ អធិរាជ ខ្លូដទីពីរ ក៏បានបញ្ជាឲ្យគេយកវ៉ាឡង់តាំង ទៅប្រហារជីវិតដោយគ្មានអាណិតអាសូរ។

នៅថ្ងៃទី ១៤ កុម្ភៈ ឆ្នាំ ២៦៩ វ៉ាឡង់តាំង ត្រូវបានពួកទាហានវាយធ្វើបាបជាខ្លាំង តែមិនព្រមស្លាប់ ក៏ត្រូវបានគេប្រហារជីវិតដោយកាត់ក្បាល។ បន្ទាប់ពីច្រើនឆ្នាំក្រោយមក នៅឆ្នាំ ៤៩៤ សម្តេចប៉ាប Gélase ទី១ បានសម្រេចចិត្តហាមឃាត់នូវការធ្វើបុណ្យ Lupercales នៅថ្ងៃ ១៥ កុម្ភៈ។ គាត់បានដាក់

ជំនួសវិញ គឺការធ្វើបុណ្យ Saint Valentin នៅថ្ងៃ ១៤ កុម្ភៈ គឺជាថ្ងៃដែល វ៉ាឡង់តាំង បានទទួលមរណៈភាព។

គួរបញ្ជាក់ដែរថា ប្រវត្តិវិទូខ្លះបានដាក់ថា Valentin មិនបានកើតនៅ គ.ស.ទី ៥ ទេ គឺគាត់បានកើតនៅរវាងពីរឬបីស.វ.ក្រោយមកនៅយុគកណ្តាល ដូចដែលយើងបានរៀបរាប់មកខាងលើនេះ,បុណ្យ Saint Valentinមិនមែនទើបតែបង្កើតឡើងនាសម័យទំនើបនេះទេ។ អ្នករកស៊ីលក់ផ្កា នឹងអ្នករកស៊ីលក់ស្ូកូឡា គ្រាន់តែរកចំណេញពីព្រឹត្តិការណ៍ដ៏មានចំណាស់កាលតែប៉ុណ្ណោះ។ បុណ្យនេះគឺមានតាំងពីដើម នៃគ្រិស្តសតវត្សរ៍មកម្លេះ។

ប្រភព: www.histoire-fr.com ប្រែសម្រួលជាភាសារខ្មែរដោយ កូនខ្មែរបារាំង ឯកសារជំនួយ: Dictionnaire Petit Larousse 1991 នឹង វចនានុក្រម បារាំង-ខ្មែរ ភាគទី១ ភាគ ទី២ របស់លោក តិប យក់ នឹង ថាវ គន្ធ បោះពុម្ពនៅឆ្នាំ ១៩៦៤ ដោយបណ្ណាគារ ប៊ុត នាង។

បើគួរពុំគួរ សូមមេត្តាអភ័យទោស,

សូមអរគុណ